クメール語



ប្រចាំឆ្នាំ2022

ក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈក្រុងអាយាសិ

សេចក្តីណែនាំ

# 令和4年度

# 綾瀬市公設放課後児童クラブのご案内



クメール語（カンボジア）



Ayapi

ប្រចាំឆ្នាំ2022

# ក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈក្រុងអាយាសិ

## សេចក្ដីណែនាំ

**<<មាតិកា>>**


1 អំពីការបើកក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ ..... 1

2 សង្ខេបអំពីក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ ..... 1

(1) រយៈពេលបើក

(2) កន្លែងបើក

(3) ថ្ងៃបើក និងម៉ោងបើកជាដើម

(4) កុមារដែលអាចចូលរៀន(ជាគោល កុមារដែលបំពេញលក្ខខណ្ឌទាំងអស់ខាងក្រោមអាចចូលរៀន)

(5) លក្ខខណ្ឌការងាររបស់អាណាព្យាបាលចាំបាច់ចូលរៀន

(6) ប្រាក់បន្ទុករបស់អាណាព្យាបាល។ល។

(7) ខ្លឹមសារណែនាំ

(8) វិធីដាក់ពាក្យនិងការអនុញ្ញាតចូលរៀន

3 ការប្រើប្រាស់ក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ ..... 7

(1) ពន្យល់អំពីការចូលរៀន

(2) អំពីឯកសារដាក់ក្រោយសម្រេចចូលរៀន

(3) របស់យកមក

(4) អំពីការជូននិងទទួលកូន

(5) អំពីជំងឺឆ្លងជាដើម

(6) អំពីករណីបិទថ្នាក់សិក្សា

(7) អំពីគ្រោះមហន្តរាយដូចជារញ្ជួយដី និងខ្យល់ព្យុះជាដើម

4 អំពីសកម្មភាពនៅក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ ..... 12

(1) សកម្មភាពពេញថ្ងៃ(ឧទាហរណ៍)

(2) ការរៀបចំបិនតូ

(3) ការហាមឃាត់ចេញកណ្ដាលម៉ោង

5 អំពីការដោះស្រាយពេលអាសន្ន ..... 13

(1) អំពីដំណោះស្រាយនៃការហ្វឹកហាត់ជម្លៀសនៅសាលា និងការចុះពីសាលាជាក្រុម

(2) ករណីជំងឺនៃកុមារ និងពេលអាសន្នផ្សេងទៀត

6 ពាក្យជូនដំណឹងអំពីការផ្លាស់ប្ដូរ និងពាក្យជូនដំណឹងអំពីឈប់ចេញពីសាលា ..... 13

(1) ការផ្លាស់ប្ដូរអាសយដ្ឋាន និងស្ថានភាពការងារ។ល។

(2) បែបបទពេលអវត្តមានយូរ និងពេលឈប់ចេញពីសាលា

7 ផ្សេងទៀត ..... 14

8 ទំនាក់ទំនង ..... 14

9 បញ្ជីក្លឹបកុមារក្រោយម៉ោងសាលាឯកជនក្នុងក្រុង ..... 15

**10 ផែនទីទីតាំងក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈនិងឯកជនក្នុងក្រុងអាយាសិ ..... 16**

# 令和4年度
# 綾瀬市公設放課後児童クラブのご案内



あやぴぃ

## ≪ 目　次 ≫


**1　公設放課後児童クラブの開設について・・・・・・・・・・・・・・・・・・・・・1ページ**

**2　公設放課後児童クラブの概要・・・・・・・・・・・・・・・・・・・・・・・・1ページ～**

（１）開設期間
（２）開設場所
（３）開所日、開所時間など
（４）入所対象児童
（５）入所に必要な保護者の就労条件
（６）保護者負担金など
（７）指導内容
（８）申請方法、入所の承認などについて

**3　公設放課後児童クラブの利用にあたって・・・・・・・・・・・・・・・・・・7ページ～**

（１）入所の説明
（２）入所決定後の提出書類について
（３）持ち物
（４）児童の送迎について
（５）感染症などについて
（６）学級閉鎖等の場合について
（７）地震、台風などの災害について

**4　公設放課後児童クラブでの過ごし方について・・・・・・・・・・・・・・・12ページ**

（１）１日の過ごし方（例）
（２）お弁当の用意
（３）中抜けの禁止

**5　緊急時の対応について・・・・・・・・・・・・・・・・・・・・・・・・・・13ページ**

（１）学校の避難訓練、集団下校の対応について
（２）児童の病気、その他の緊急時の場合

**6　変更届、退所届について・・・・・・・・・・・・・・・・・・・・・・・・・13ページ**

（１）住所や勤務状況等の変更など
（２）休所、退所の手続き

**7　その他・・・・・・・・・・・・・・・・・・・・・・・・・・・・・・・・・14ページ**

**8　問い合わせ先・・・・・・・・・・・・・・・・・・・・・・・・・・・・・・14ページ**

**9　市内の民設民営放課後児童クラブ一覧・・・・・・・・・・・・・・・・・・15ページ**

**10　綾瀬市公設・民設放課後児童クラブ位置図・・・・・・・・・・・・・・・・16 ページ**

# 1 អំពីការបើកក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ

ទីក្រុងអាយាសិមានរៀបចំក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈសម្រាប់កុមារ ដែលអាណាព្យាបាលត្រូវបានចាត់ទុកថាមិនអាចចិញ្ចឹមកូនបានល្អនៅផ្ទះនៅពេលថ្ងៃ ដោយសារការងារ ឬជំងឺជាដើម ហើយចាប់បើកពីខែមេសាឆ្នាំ2016។

ក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈដែលបង្កើតឡើងដោយក្រុង គឺក្រុងពឹងពាក់ប្រតិបត្តិករដែលបានជ្រើសរើសចំពោះការងារនេះ ហើយគ្រូដែលមានសមត្ថភាពផ្តល់ការណែនាំដល់កុមារ ខណៈពេលដែលទទួលបានការយោគយល់ និងកិច្ចសហប្រតិបត្តិការពីគ្រួសារ និងអ្នកនៅក្នុងសហគមន៍។ តាមរយៈជីវភាព និងការលេងនៅក្លឹប យើងលើកទឹកចិត្តឱ្យមានការអភិវឌ្ឍន៍ ការរីកចម្រើន និងឯករាជ្យភាពរបស់បុគ្គលម្នាក់ៗ ទន្ទឹមនឹងនោះ បណ្តុះភាពសហការនិងភាពចុះសង្គម ខណៈគ្រប់គ្រងដើម្បីឱ្យអាចរស់នៅសប្បាយរីករាយក្នុងក្រុម។

# 2 សង្ខេបអំពីក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ

## (1) រយៈពេលបើក

ចាប់ពីថ្ងៃ1ខែមេសាឆ្នាំ2022 ដល់ថ្ងៃ31ខែមីនាឆ្នាំ2023

**※ដោយសារពាក្យសុំសម្រាប់ឆ្នាំសិក្សានីមួយៗ សូម្បីតែអ្នកដែលទទួលបានការអនុញ្ញាតចូលរៀននៅឆ្នាំ2021 ប្រសិនបើចង់ប្រើប្រាស់នៅឆ្នាំ2022 នឹងត្រូវដាក់ពាក្យតាមឆ្នាំនោះទៀត។**

## (2) កន្លែងបើក

| ឈ្មោះក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ | បែងចែកសាលាសំខាន់ៗ | អាសយដ្ឋាន | ទូរសព្ទ | ចំនួនកំណត់ |
|---|---|---|---|---|
| ក្លឹបកុមារក្រោយម៉ោងសាលាបឋមអាយាសិ | បឋមអាយាសិ | 5-1-1 Fukayanaka | 0467-98-7043 | 40នាក់ |
| ក្លឹបកុមារក្រោយម៉ោងសាលាNagagutsu | បឋម Ryosei | 2-11-14 Ryosei | 0467-98-7092 | 35នាក់ |
| ក្លឹបកុមារក្រោយម៉ោងសាលាបឋមOchiai | បឋមOchiai | 3-10-1 Ochiaikita | 0467-98-7277 | 40នាក់ |
| ក្លឹបកុមារក្រោយម៉ោងសាលាបឋមTsuchidana | បឋម Tsuchidana | 6-1-1 Kamitsuchidanaminami | 0467-91-7347 | 32នាក់ |

**※សម្រាប់ការសាកសួរអំពីគ្រឹះស្ថាន សូមទាក់ទងតាមកន្លែងនីមួយៗ និងសម្រាប់ការសាកសួរអំពីបែបបទដាក់ពាក្យជាដើម សូមទាក់ទងផ្នែកមើលថែកុមារ (0467-70-5682 / ខលសិនធ័របកប្រែភាសាបរទេសទីក្រុងអាយាសិ)។**

## １　公設放課後児童クラブの開設について

綾瀬市では、保護者が就労や疾病等により、昼間家庭において、児童に健全な育成を行うことができないと認められる家庭の児童を対象とした公設放課後児童クラブの整備を行い、平成２８年４月より開設しています。

市が開設する公設放課後児童クラブは、市が選定した事業者に業務を委託し、資格を持った指導員等が家庭や地域の方々などの理解や協力を得ながら児童の指導にあたります。クラブでの生活や遊びを通して、一人一人の発達や成長、自立を促すとともに、協調性や社会性を養いながら、集団の中で楽しく過ごすことができるよう、運営を行っています。

## ２　公設放課後児童クラブの概要

### （１）開設期間

令和４年４月１日から令和５年３月３１日まで

**※年度ごとの申込のため、令和３年度に入所承認を受けた方についても、令和４年度の利用を希望される場合は、その都度申請いただきます。**

### （２）開設場所

| 公設放課後児童クラブ名 | 主な学区 | 所　在　地 | 電話番号 | 定員 |
|---|---|---|---|---|
| 綾瀬小放課後児童クラブ | 綾瀬小 | 深谷中５－１－１ | 0467-98-7043 | 40 名 |
| ながぐつ放課後児童クラブ | 綾西小 | 綾西２－１１－１４ | 0467-98-7092 | 35 名 |
| 落合小放課後児童クラブ | 落合小 | 落合北３－１０－１ | 0467-98-7277 | 40 名 |
| 土棚小放課後児童クラブ | 土棚小 | 上土棚南６－１－１ | 0467-91-7347 | 32 名 |

**※施設に関するお問い合わせは各施設まで、申請手続き等に関するお問い合わせは保育課（０４６７-７０-５６８２／綾瀬市外国語通訳コールセンター）までお願いいたします。**

## (3) ថ្ងៃបើក និងម៉ោងបើកជាដើម

### ថ្ងៃបើក និងម៉ោងមើលថែ

①ថ្ងៃក្រៅពីថ្ងៃឈប់សម្រាករបស់សាលា៖ ក្រោយចប់ថ្នាក់រៀន ដល់ម៉ោង8យប់

②ថ្ងៃសម្រាកថ្នាក់រៀនរបស់សាលា៖ ម៉ោង8ព្រឹក ដល់ ម៉ោង8យប់

※ល្ងាចពីម៉ោង7ដល់ម៉ោង8 ជាម៉ោងមើលថែបន្ថែម។

### ថ្ងៃឈប់សម្រាក

①ថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាកដែលកំណត់ដោយច្បាប់ក្នុងថ្ងៃបុណ្យជាតិ

②ថ្ងៃ2,3ខែមករា, និងថ្ងៃ29ដល់31ខែធ្នូ

**※ប្រសិនបើឃើញថាពិបាកបើកក្លឹបដោយសារគ្រោះមហន្តរាយជាដើម ក្លឹបអាចនឹងបិទជាបណ្ដោះអាសន្ន។**

## (4) កុមារដែលអាចចូលរៀន(ជាគោល កុមារដែលបំពេញលក្ខខណ្ឌទាំងអស់ខាងក្រោមអាចចូលរៀន)

①កុមារដែលមានអាសយដ្ឋាននៅទីក្រុងអាយាសិ និងកំពុងរៀននៅសាលាបឋម

②កុមារដែលមិនអាចទទួលបានការចិញ្ចឹមបានល្អនៅផ្ទះនៅពេលថ្ងៃ ដោយសារការងារ ជម្ងឺ ឬហេតុផលផ្សេងៗរបស់អាណាព្យាបាល

**※យើងមិនអាចទទួលកុមារ ក្រៅពីមូលហេតុដែលបានជូនដំណឹងពេលដាក់ពាក្យចូលរៀន និងមូលហេតុផ្ទាល់ខ្លួនបានទេ។**

**※ដើម្បីសុវត្ថិភាពកុមារ សូមទៅយកកូនចេញពីក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈចាប់ពីម៉ោង5ល្ងាចពុំខាន។ សូមមកទទួលកូននៅត្រឹមម៉ោងចប់ (ម៉ោង7យប់, ប្រសិនបើស្នើរសុំមើលថែបន្ថែមម៉ោង8យប់) ជាកំហិត។**

## (5) លក្ខខណ្ឌការងាររបស់អាណាព្យាបាលចាំបាច់ចូលរៀន

・ម៉ោងធ្វើការចាប់ពី64ម៉ោងក្នុង1ខែ

※ក្រៅពីការងារពេញម៉ោង, ការងារមូលដ្ឋានទាំងអស់ដូចជាការងារក្រៅម៉ោង និងការងារពេលយប់។

（３）開所日、開所時間など

開所日、保育時間

①学校の授業の休業日以外の日：授業の終了後から午後８時まで

②学校の授業の休業日：午前８時から午後８時まで

※午後７時から８時までは、延長保育時間となります。

休所日

①日曜日及び国民の祝日に関する法律に規定する休日

②１月２日、同月3日及び１２月２９日から同月３１日まで

**※災害等によりクラブ開所が困難と認められる場合は、臨時に休所することがあります。**

（４）入所対象児童（原則として、次の要件をいずれも満たす児童が入所の対象者となります。）

①綾瀬市に住所を有し、小学校に就学している児童

②保護者の就労、疾病その他の理由により、昼間家庭において健全な育成を受けられない児童

**※入所申請時に届出された理由以外や私的な用事では、お預かりできません。**

**※児童の安全を考え、午後５時以降は必ず公設放課後児童クラブへの送迎を行ってください。迎えは開所時間終了時刻（午後７時。延長保育の申請をした場合は午後８時。）までに来ていただけることが前提となっております。**

（５）入所に必要な保護者の就労条件

・１か月当たりの就労時間が６４時間以上

※フルタイムのほか、パートタイムや夜間など基本的全ての就労が当てはまります。

## (6) ប្រាក់បន្ទុករបស់អាណាព្យាបាល។ល។

①ថ្លៃមើលថៃ(រួមទាំងធានារ៉ាប់រងសុខភាព+ថ្លៃអាហារសម្រន់)
ថ្នាក់សិក្សាទាប (ថ្នាក់ទី1ដល់ទី3): ទឹកប្រាក់ប្រចាំខែ13,000យ៉េន
ថ្នាក់សិក្សាខ្ពស់ (ថ្នាក់ទី4ដល់ទី6): ទឹកប្រាក់ប្រចាំខែ10,000យ៉េន
(ការបង់ថ្លៃមើលថៃ ជាគោលតាមការផ្ទេរតាមគណនីធនាគារ។)

②ថ្លៃមើលបន្ថែមម៉ោង
កុមារ1នាក់ 1លើក 500យ៉េន(ទឹកប្រាក់កម្រិតប្រចាំខែគឺ2,500យ៉េន)
(ការបង់ថ្លៃមើលថៃបន្ថែមម៉ោង ជាគោលតាមការផ្ទេរតាមគណនីធនាគារនៅខែបន្ទាប់នៃខែប្រើប្រាស់។)

**※ការចុះថ្លៃចំពោះបងប្អូនបង្កើត**
ប្រសិនបើ1គ្រួសារមួយមានកូនចាប់ពី2នាក់ ចំពោះកុមារដែលមិនមែនរៀនថ្នាក់ខ្ពស់បំផុត(ប្រសិនបើមានកុមារចាប់ពី2នាក់ដែលរៀនថ្នាក់ខ្ពស់បំផុត គឺយកតែ1នាក់)ដែលចូលរៀននៅក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ, ចំនួនថ្លៃមើលថៃពេលចូលរៀនគឺគិតពាក់កណ្តាល។

**※ក្នុងករណីខាងក្រោមនេះ មានប្រព័ន្ធលើកលែងថ្លៃមើលថៃទាំកុមារ។ល។ ចាំបាច់ស្នើសុំដើម្បីប្រើប្រាស់ប្រព័ន្ធ។ សម្រាប់ព័ត៌មានលម្អិត សូមសាកសួរមកផ្នែកមើលថៃកុមារ។**
គ្រួសារដែលមានការគាំពារជីវភាព, គ្រួសារដែលត្រូវបានលើកលែងពន្ធក្រុង, និងគ្រួសារដែលអាណាព្យាបាលទទួលបានការឧបត្ថម្ភក្រោមបទប្បញ្ញត្តិនៃ "ច្បាប់ស្តីពីការលើកកម្ពស់ការវិលត្រឡប់ដោយរលូននៃប្រជាជនជប៉ុននៅសល់ក្រោយសង្គ្រាមក្នុងប្រទេសចិន។ល។ និងការជួយភាពម្ចាស់ការដល់ប្រជាជនជប៉ុននៅសល់ក្រោយសង្គ្រាមក្នុងប្រទេសចិនដែលបានត្រលប់មករស់នៅប្រទេសជប៉ុនជាអចិន្ត្រៃយ៍ព្រមទាំងប្តីប្រពន្ធជាក់លាក់", គ្រួសារដែលមានជីវភាពក្រលំបាកខ្លាំងដោយសារភាពអត់ការងារធ្វើ ជំងឺជាដើម និងគ្រួសារដែលមានជីវភាពក្រលំបាកខ្លាំងដោយសារតែកាលៈទេសៈដែលមិនអាចជៀសបាន ដូចជាគ្រោះមហន្តរាយជាដើម។

※ថ្លៃមើលថៃនឹងត្រូវបានប្រមូល ទោះបីជាកុមារអវត្តមានរយៈពេលយូរក៏ដោយ។
※មិនមានការចុះថ្លៃបងប្អូន សម្រាប់ថ្លៃមើលថៃបន្ថែមទេ។

②សាមាគមអាណាព្យាបាល
ការប្រជុំពន្យល់ដល់អាណាព្យាបាល(ការប្រជុំអាណាព្យាបាល) ធ្វើឡើងជារៀងរាល់ឆមាសក្នុងគោលបំណងរាយការណ៍អំពីសកម្មភាពរបស់កុមារក្នុងក្លឹប និងការប្រាស្រ័យទាក់ទងរវាងឪពុកម្តាយដូចគ្នា។

## (7) ខ្លឹមសារណែនាំ

យើងនឹងរៀបចំបរិយាកាសសមរម្យសម្រាប់ជាកន្លែងដែលកុមារនៅដោយស្រួលចិត្ត និងអាចឱ្យកុមារជៀសផុតពីគ្រោះថ្នាក់ដោយខ្លួនឯងដោយយកចិត្តទុកដាក់លើសុវត្ថិភាព ហើយដើម្បីអាចលេងកំសាន្តនិងរស់នៅដោយម្ចាស់ការ ស្របតាមដំណាក់កាលនៃការអភិវឌ្ឍន៍របស់កុមារយើងខិតខំអប់រំបណ្តុះបណ្តាលកុមារដោយធ្វើឱ្យប្រសើរឡើងនូវឯករាជ្យភាព, សង្គម និងគំនិតច្នៃប្រឌិត និងបង្កើតទម្លាប់នៃការរស់នៅជាមូលដ្ឋាន។

（６）保護者負担金など

①保育料（保険料、おやつ代を含む金額）

低学年（１年生から３年生まで）：月額１３，０００円

高学年（４年生から６年生まで）：月額１０，０００円

（保育料の納付方法は、原則として口座振替とさせていただきます。）

②延長保育料

児童１人につき１回５００円（月の限度額は２，５００円）

（延長保育料の納付方法は、原則として利用月の翌月に口座振替とさせていただきます。）

※兄弟割引について

１世帯につき２人以上の児童が入所した場合の保育料の額は、最も学年の高い児童（最も学年の高い児童が２人以上いる場合は、いずれか１人とする。）を除く児童が公設放課後児童クラブに入所する場合については、保育料の額を２分の１の額とします。

**※次に該当する場合は、保育料等の減免制度があります。制度の利用には申請が必要です。詳しくは、保育課にお問い合わせください。**

**生活保護世帯、市民税非課税世帯、保護者が「中国残留邦人等の円滑な帰国の促進並びに永住帰国した中国残留邦人等及び特定配偶者の自立の支援に関する法律」の規定による支援給付を受けている世帯、失業疾病等により収入が全く得られなくなり生活が著しく困窮している世帯、災害等やむを得ない事情により生活が著しく困窮している世帯**

※保育料は、長期欠席の場合でも徴収させていただきます。

※延長保育料については、兄弟割引はありません。

②保護者会

クラブでの子どもの様子の報告や保護者同士の交流を目的として、学期ごとに保護者説明会（保護者会）を開催します。

（７）指導内容

児童が安心して過ごせる生活の場として相応しい環境を整え、安全面に配慮しながら子どもが自ら危険を回避できるようにしていくとともに、児童の発達段階に応じた主体的な遊びや生活が可能となるように、自主性、社会性及び創造性の向上、基本的な生活習慣の確立等により、児童の健全な育成を図ります。

## (8) វិធីដាក់ពាក្យនិងការអនុញ្ញាតចូលរៀន

①រយៈពេលជ្រើសរើស

**រយៈពេលជ្រើសរើសសម្រាប់អ្នកចង់ចូលថ្ងៃ1ខែមេសា**

**ចាប់ពីថ្ងៃ11(អង្គារ)ខែមករាឆ្នាំ2022 ដល់ ថ្ងៃ26(ពុធ)ខែមករាឆ្នាំ2022**

※ការពិនិត្យសម្រេចការចូលរៀននៃអ្នកដែលបានដាក់ពាក្យក្រោយរយៈពេលជ្រើសរើសខាងលើ គឺត្រូវបានធ្វើតាមក្រោយបញ្ចប់ការពិនិត្យសម្រេចអ្នកដែលបានដាក់ពាក្យក្នុងរយៈពេល។

**ក្រោយរយៈពេលជ្រើសរើសខាងលើ**

※**យើងជ្រើសរើសតែក្នុងករណីមានការខ្វះចំនួនប៉ុណ្ណោះ។**

※**ប្រសិនបើមិនខ្វះទេ នឹងត្រូវបានចុះឈ្មោះរង់ចាំ។ (ប្រសិនបើបានដាក់ពាក្យម្តងរួចហើយ មិនចាំបាច់ដាក់ពាក្យសាជាថ្មីក្នុងឆ្នាំសិក្សានោះទេ។**

②ឯកសារចាំបាច់ក្នុងការដាក់ពាក្យ

(ⅰ) ពាក្យសុំចូលក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ(ទម្រង់លេខ1) ※1សន្លឹកសម្រាប់កុមារ1នាក់

・ប្រសិនបើកំពុងស្នាក់នៅជាមួយតាយាយជាដើម ដាច់ខាងសូមសរសេរក្នុងក្រឡោន "គ្រួសារស្នាក់នៅជាមួយកុមារចូលរៀន"។

(ⅱ) លិខិតបញ្ជាក់ការងារ(ទម្រង់លេខ2)។ល។

・ចាំបាច់បញ្ជាក់គ្រប់គ្នាដែលមានអាយុក្រោម65ឆ្នាំ ធ្វើការ និងកំពុងស្នាក់នៅជាមួយ។ សូមដាក់ដោយយោងតារាងក្នុងទំព័របន្ទាប់។

(ⅲ) ប័ណ្ណសិក្សាពិនិត្យកុមារ(ទម្រង់លេខ3) ※1សន្លឹកសម្រាប់កុមារ1នាក់

(ⅳ) ពាក្យសុំលើកលែងថ្លៃមើលថែក្នុងក្លឹបកុមារក្រោយម៉ោងសាលា(ទម្រង់លេខ3) និងឯកសារបញ្ជាក់(សម្រាប់អ្នកដែលមាន)

(ⅴ) ពាក្យសុំមើលថែបន្ថែមម៉ោងក្នុងក្លឹបកុមារក្រោយម៉ោងសាលា(ទម្រង់លេខ6)(តាមអ្នកចង់បាន)

※**សម្រាប់(ⅰ)ដល់(ⅲ) មានចែកនៅផ្នែកមើលថែកុមារ។**

※**សម្រាប់(ⅰ)ដល់(ⅴ) អាចដោនឡូតពីគេហទំព័រក្រុង។**

★អាសយដ្ឋានគេហទំព័រក្រុង ★

http://www.city.ayase.kanagawa.jp

（８）申請方法、入所の承認などについて

①募集期間

４月１日入所希望者の募集期間

令和４年1月１１日（火）から1月２６日（水）まで

※上記募集期間後に申請された方の入所審査は、期間内に申請した方の審査終了後になります。

上記募集期間後

**※定員に空きがある場合のみ、随時募集します。**

**※空きがない場合は、待機として登録されます。（一度提出されれば、年度内の申込についての再提出は不要です。）**

②申請に必要なもの

（ⅰ）放課後児童クラブ入所申請書（第１号様式）※児童１人につき１枚

・祖父母等と同居している場合は、「入所児童の同居の家族」の欄に必ず記入してください。

（ⅱ）就労証明書（第２号様式）など

・同居している６５歳未満の就労している方全員の証明が必要です。次ページの表を参考にご提出ください。

（ⅲ）児童調査票（第３号様式）※児童１人につき１枚

（ⅳ）放課後児童クラブ保育料等減免申請書（第３号様式）及び証明書類（該当者のみ）

（ⅴ）放課後児童クラブ延長保育申請書（第６号様式）（希望者のみ）

**※（ⅰ）～（ⅲ）については、保育課で配布します。**

**※（ⅰ）～（ⅴ）については、市ホームページからダウンロードもできます。**

★市ホームページアドレス★

http://www.city.ayase.kanagawa.jp

<<(ii) ឯកសារភ្ជាប់ចាំបាច់សម្រាប់លិខិតបញ្ជាក់ការងារ>>

| មូលហេតុចង់ចូលរៀន | ឯកសារភ្ជាប់ចាំបាច់ |
|---|---|
| កំពុងធ្វើការ(ជាប់ការជ្រើសរើសការងារ) | ·លិខិតបញ្ជាក់ការងារ(ទម្រង់លេខ2) |
| ដោយសារជំងឺ, របួស, ពិការ | ·លិខិតពិនិត្យរបស់វេជ្ជបណ្ឌិត(មានសរសេរឈ្មោះជំងឺ និងរយៈពេលព្យាបាល។ ថតចម្លងបាន)<br>·ថតចម្លងសៀវភៅជនពិការរាងកាយ<br>·ថតចម្លងសៀវភៅសុភាពនិងសុខុមាលភាពជនពិការសតិ<br>·ថតចម្លងសៀវភៅនីតិសម្បទា |
| ដោយសារថែទាំសាច់ញាតិជាប្រចាំ | ·លិខិតពិនិត្យរបស់វេជ្ជបណ្ឌិតដែលបញ្ជាក់ពីស្ថានភាពសុខភាពរបស់អ្នកដែលត្រូវការការថែទាំ<br>(មានសរសេរឈ្មោះជំងឺ និងរយៈពេលនៃការព្យាបាល។ ថតចម្លងបាន)<br>·ថតចម្លងសៀវភៅជនពិការរាងកាយ<br>·ថតចម្លងសៀវភៅសុភាពនិងសុខុមាលភាពជនពិការសតិ<br>·ថតចម្លងសៀវភៅស្តារនីតិសម្បទា |
| ដោយសារកំពុងរៀននៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីធ្វើការ | ·លិខិតបញ្ជាក់ការសិក្សា(មានសរសេររយៈពេល), កាលវិភាគ |
| ដោយសារម្តាយសម្រាលកូន(គ្រោង) | ·ថតចម្លងសៀវភៅសុខភាពមាតាទារក(មានទំព័រគ្របនិងមានសរសេរថ្ងៃគ្រោងសម្រាល)<br>※នៅចន្លោះសល់សូមសរសេរ "ឈ្មោះកុមារ, ថ្ងៃខែឆ្នាំកំណើតកុមារ, ឈ្មោះសាលាបឋម(គ្រោង)ចូលរៀន"។ |
| ដោយសារកំពុងស្វែងរកការងារ(រួមទាំងការរៀបចំចាប់ផ្តើមអាជីវកម្ម) | ·កាតស្វែងរកការងារ / វិញ្ញាបនបត្រអ្នកទទួលផលធានារ៉ាប់រងការងារ<br>·ពាក្យសុំស្វែងរកការងារ ឬលិខិតសម្បថ |
| ដោយសារកំពុងឈប់សម្រាកមើលថែទាំកូន | ·លិខិតបញ្ជាក់រយៈពេលទទួលបានការឈប់សម្រាកថែទាំកូន / លិខិតបញ្ជាក់ការឈប់សម្រាកថែទាំកូន<br>·សេចក្តីជូនដំណឹងអំពីការសម្រេចផ្តល់ប្រាក់ឧបត្ថម្ភដល់ការឈប់សម្រាកថែទាំកូន |
| ក្នុងករណីអាជីវភាពផ្ទាល់ខ្លួន | ក្រៅពីលិខិតបញ្ជាក់ការងារ, ត្រូវការឯកសារមួយណាខាងក្រោម<br>·ថតចម្លងពាក្យជូនដំណឹងបើកអាជីវកម្មផ្ទាល់ខ្លួន<br>·ថតចម្លងលិខិតអនុញ្ញាតអាជីវកម្ម<br>·ថតចម្លងវិញ្ញាបនបត្រនៃប្រការចុះបញ្ជី<br>·ថតចម្លងឯកសារដែលបញ្ជាក់ប្រាក់ចំណូលអាជីវកម្ម ដូចជាលិខិតប្រកាសពន្ធ(ចុងសន្លឹក)<br>·កំណត់ត្រាបញ្ជាក់អាជីវកម្មផ្ទាល់ខ្លួន(ទាមទារឈ្មោះ និងត្រារបស់មន្ត្រីសុខុមាលភាពមូលដ្ឋាន)<br>·ឯកសារដែលអាចបញ្ជាក់អាជីវកម្មផ្ទាល់ខ្លួនផ្សេងទៀត |

《（ⅱ）就労証明書などにおける必要添付書類》

| 入所を希望する理由 | 必要添付書類 |
|---|---|
| 勤務している（就労が内定している）ため | ・就労証明書（第２号様式） |
| 疾病、負傷、障害のため | ・医師の診断書（病名・療養期間の記載のあるもの。写しも可）<br>・身体障害者手帳の写し<br>・精神障害者保健福祉手帳の写し<br>・療育手帳の写し |
| 親族を常時介護しているため | ・介護を要する者の病状等が記載された医師の診断書（病名や療養期間の記載のあるもの。写しも可）<br>・身体障害者手帳の写し<br>・精神障害者保健福祉手帳の写し<br>・療育手帳の写し |
| 就業を目的として学校・職業訓練校等に就学しているため | ・在学証明書（期間のあるもの）、時間割 |
| 母親が出産（予定）のため | ・母子手帳の写し（表紙と出産予定日の記入されたページ）<br>※余白に「児童氏名、児童生年月日、在籍（予定）小学校名」を記入してください。 |
| 求職活動中（起業準備を含む）のため | ・求職カード・雇用保険受給者資格証<br>・求職活動申立書・誓約書のいずれか |
| 育児休業中のため | ・育児休業取得期間証明書・育児休業証明書<br>・育児休業給付金支給決定通知書のいずれか |
| 自営業の場合 | 就労証明書の他に、次のいずれかの書類<br>・個人事業の開業届の写し<br>・営業許可書の写し<br>・登記事項証明書の写し<br>・確定申告書（控）等の事業の収入を証明するものの写し<br>・自営業確認調書（民生委員の記名及び捺印が必要）<br>・その他自営が確認できる書類 |

③កន្លែងនិងវិធីដាក់ពាក្យចូលរៀន

## កុមារដែលមានបំណងចូលក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈចាប់ពីថ្ងៃ1ខែមេសា

・សូមដាក់ឯកសារ "ឯកសារចាំបាច់ក្នុងការដាក់ពាក្យ" ពី(i)ដល់(v) ទៅផ្នែកមើលថែកុមារ (ចំពោះការដាក់ពាក្យតាមប្រៃសណីយ៍ ត្រូវដល់ក្នុងរយៈពេលទទួលពាក្យសុំជាកំហិត)។

・ព័ត៌មានលម្អិតនៃម៉ោងទទួលមានដូចខាងក្រោម។ សូមបញ្ជាក់ថា កន្លែងទទួលគឺមានតែនៅផ្នែកមើលថែកុមារប៉ុណ្ណោះ។

【រយៈពេលទទួលឯកសារដាក់ពាក្យ】

| ថ្ងៃម៉ោង | ម៉ោងទទួល | កន្លែងទទួល |
|---|---|---|
| ថ្ងៃ11(អង្គារ)ខែមករា ដល់ ថ្ងៃ21(សុក្រ)ខែមករាឆ្នាំ2022 ※លើកលែងថ្ងៃសៅរ៍និងអាទិត្យ | ព្រឹក ម៉ោង8:30 ដល់ 12:00<br>រសៀលម៉ោង1 ដល់ ម៉ោង5 | ជាន់ទី2 សាលាក្រុងអាយាសិ<br>ផ្នែកមើលថែកុមារ |
| ថ្ងៃ22(សៅរ៍)ខែមករា<br>ថ្ងៃ23(អាទិត្យ)ខែមករាឆ្នាំ2022 | ព្រឹកម៉ោង8:30 ដល់ 12:00 | ជាន់ទី2 សាលាក្រុងអាយាសិ<br>ផ្នែកមើលថែកុមារ |
| ថ្ងៃ24(ច័ន្ទ)ខែមករា<br>ថ្ងៃ25(អង្គារ)ខែមករាឆ្នាំ2022 | ព្រឹក ម៉ោង8:30 ដល់ 12:00<br>រសៀលម៉ោង1 ដល់ ម៉ោង5 | ជាន់ទី2 សាលាក្រុងអាយាសិ<br>ផ្នែកមើលថែកុមារ |
| ថ្ងៃ26(ពុធ)ខែមករាឆ្នាំ2022 | ព្រឹក ម៉ោង8:30 ដល់ 12:00<br>រសៀលម៉ោង1 ដល់ ម៉ោង7 | ជាន់ទី2 សាលាក្រុងអាយាសិ<br>ផ្នែកមើលថែកុមារ<br>※ចាប់ពីល្ងាចម៉ោង5 សូមប្រើច្រកចូលពេលយប់។ |

## ក្រោយរយៈពេលជ្រើសរើសខាងលើ

※យើងជ្រើសរើសតែក្នុងករណីមានការខ្វះចំនួនប៉ុណ្ណោះ។

※ប្រសិនបើមិនខ្វះទេ នឹងត្រូវបានចុះឈ្មោះរង់ចាំ។ (ប្រសិនបើបានដាក់ពាក្យម្តងរួចហើយ មិនចាំបាច់ដាក់ពាក្យសាជាថ្មីក្នុងឆ្នាំសិក្សានោះទេ។

【ប្រការប្រុងប្រយ័ត្នពេលដាក់ពាក្យ】

・ចំពោះអ្នកដែលត្រូវលើកលែងថ្លៃមើលថែ ហើយចង់ប្រើប្រព័ន្ធនេះ ចាំបាច់ដាក់ពាក្យសុំលើកលែងថ្លៃ②(iv) និងឯកសារបញ្ជាក់។

・ចំពោះអ្នកចង់បានការមើលថែបន្ថែមម៉ោង ចាំបាច់ដាក់ពាក្យសុំមើលថែបន្ថែមម៉ោង②(v)។

・ការដាក់ពាក្យតាមប្រៃសណីយ៍ ត្រូវដល់ក្នុងរយៈពេលទទួលពាក្យសុំជាកំហិត។

③入所申請場所・方法

## 公設放課後児童クラブへ４月１日からの入所を希望する児童

・保育課に【申請に必要なもの】（ｉ）から（ｖ）までの書類を提出してください（郵送申請の場合は受付期間内必着）。

・受付時間の詳細は、次のとおりです。なお、受付場所は保育課のみとなっておりますのでご了承願います。

【申請書類受付期間】

| 日時 | 受付時間 | 受付場所 |
|---|---|---|
| 令和４年１月１１日（火）<br>～１月２１日（金）<br>※土・日曜日除く | 午前８時３０分～正午<br>午後１時～午後５時 | 綾瀬市役所２階<br>保育課 |
| 令和４年１月２２日（土）<br>１月２３日（日） | 午前８時３０分～正午 | 綾瀬市役所２階<br>保育課 |
| 令和４年１月２４日（月）<br>１月２５日（火） | 午前８時３０分～正午<br>午後１時～午後５時 | 綾瀬市役所２階<br>保育課 |
| 令和４年１月２６日（水） | 午前８時３０分～正午<br>午後１時～午後７時 | 綾瀬市役所２階<br>保育課<br>※午後５時以降は夜間入口をご利用ください。 |

## 上記募集期間後

**※定員に空きがある場合のみ、随時募集します。**

**※空きがない場合は、待機として登録されます。（一度提出されれば、年度内の申込についての再提出は不要です。）**

**【申請時の注意事項】**

**・保育料の減免に該当し、制度の利用を希望される方は、②（ⅳ）減免申請書及び証明書類の提出が必要です。**

**・延長保育を希望される方は、②（ｖ）延長保育申請書の提出が必要です。**

**・郵送による申請は申請書受付期間内必着となります。**

④ការអនុញ្ញាតចូលរៀន

・ការអនុញ្ញាតិចូលរៀនសម្រាប់កុមារដែលដាក់ពាក្យក្នុងរយៈពេលជ្រើសរើសដំបូង នឹងមិនមាននៅក្នុងលំដាប់នៃការទទួលពាក្យសុំនោះទេ ប៉ុន្តែនឹងត្រូវបានអនុម័តតាមលំដាប់អាទិភាពសម្រាប់ការចូលរៀន (ថ្នាក់ទាប។ល។)។ ហើយចំពោះលទ្ធផលពិនិត្យចូលរៀន គ្រោងនឹងជូនដំណឹងទៅអាណាព្យាបាលនៅពាក់កណ្តាលខែកុម្ភៈ។

・ក្នុងករណីខ្លឹមសារនៃពាក្យសុំគឺផ្ទុយពីការពិត វានឹងមិនត្រូវបានពិនិត្យឡើយ។ហើយទោះបីក្រោយការសម្រេចចូលរៀនក៏ដោយ ការចូលរៀនអាចត្រូវបានលុបចោលនៅក្នុងករណីដូចខាងក្រោម។

(i) កុមារដែលកំពុងចូលរៀននៅក្នុងក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ មិនបានបំពេញតាមលក្ខខណ្ឌចូលរៀន(ជាគោល មានអាសយដ្ឋាននៅទីក្រុងអាយ៉ាសិ, កំពុងរៀននៅសាលាបឋម និងមិនអាចទទួលការអប់រំបណ្តុះបណ្តាលបានល្អនៅផ្ទះពេលថ្ងៃ ដោយសារការងារ ជម្ងឺ ឬហេតុផលផ្សេងទៀតរបស់អាណាព្យាបាល)។

(ii) ពេលបានទទួលការអនុញ្ញាតិចូលរៀន តាមការក្លែងបន្លំឬសកម្មភាពភូតកុហកផ្សេងទៀត

## 3 ការប្រើប្រាស់ក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ

### (1) ពន្យល់អំពីការចូលរៀន

・នៅពេលដែលអ្នកទទួលបាន "លិខិតជូនដំណឹងអំពីការអនុញ្ញាតិចូលរៀននៅក្លឹបកុមារក្រោយម៉ោងសាលា(ទម្រង់លេខ 4)" សូមមានវត្តមានក្នុងកិច្ចប្រជុំពន្យល់អ្នកចូលរៀនដែលធ្វើឡើងនៅក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈនិមួយៗមុននឹងចូលរៀន (សម្រាប់អ្នកចូលរៀននៅដើមឆ្នាំសិក្សា គ្រោងនឹងធ្វើឡើងចាប់ពីដើមដល់ពាក់កណ្តាលខែមីនា) ដើម្បីទទួលការពន្យល់។

### (2) អំពីឯកសារដាក់ក្រោយសម្រេចចូលរៀន

・សម្រាប់អ្នកដែលបានសម្រេចចូលរៀន ជាមួយនឹង"លិខិតជូនដំណឹងអំពីការអនុញ្ញាតចូលរៀននៅក្លឹបកុមារក្រោយម៉ោងសាលា(ទម្រង់លេខ 4)" សូមបំពេញព័ត៌មានចាំបាច់លើឯកសារដើម្បីបញ្ជាក់ពីស្ថានភាពកុមារ និងការឆ្លើយតបពេលអាសន្ន និងដាក់ទៅក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈនីមួយៗនៅពេលប្រជុំពន្យល់អ្នកចូលរៀន។

### (3) របស់យកមក

①របស់យកមកពេលចូលរៀន(របស់សំខាន់)

・ស្បែកជើងស្លីបព័រពាក់ក្នុងបន្ទប់(ខុសពីរបស់សាលា)

・កន្សែង

・ថង់ដាក់សំលៀកបំពាក់ផ្លាស់ប្តូរ(រាល់សំលៀកបំពាក់ផ្លាស់ប្តូរដែលរួមទាំង ខោអាវទ្រនាប់ និងស្រោមជើង)

・ថង់ផ្លាស្ទិកដាក់របស់ប្រឡាក់ទៅផ្ទះ

・មួកការពារគ្រោះមហន្តរាយឬមួកការពារ(ខុសពីរបស់សាលា)

・ក្រណាត់ជូត(1សន្លឹក)

②ថ្ងៃសៅរ៍និងពេលឈប់សម្រាករយៈពេលយូរ។ល។

・កាបូបសាកាដូជាដើម

・សម្ភារៈសិក្សា(ប្រើក្នុងម៉ោងសិក្សា។)

・បាយប្រអប់ និងដបទឹក

④入所の承認

・当初募集期間内に申請のあった児童の入所承認は、申請受付順ではなく、入所の優先順位が高い児童（低学年等）から順次承認します。
また、入所審査の結果につきましては、２月中旬に保護者へ通知する予定です。

・申請内容が事実に反したものである場合には、審査の対象としません。
また、入所決定後であっても、以下に該当する場合は入所を取り消す場合があります。

（ｉ）公設放課後児童クラブに入所している児童が、入所要件（原則として、綾瀬市に住所を有し、小学校に就学しており、保護者の就労、疾病その他の理由により、昼間家庭において健全な育成を受けられない。）を具備しなくなったとき。

（ⅱ）偽りその他不正の行為により入所の承認を受けたとき。

## ３　公設放課後児童クラブの利用にあたって

### （１）入所の説明

・「放課後児童クラブ入所承認通知書（第４号様式）」がお手元に届きましたら、入所前に各公設放課後児童クラブで実施する入所者説明会（年度当初の入所者は３月上旬から中旬実施予定）に出席いただき、説明を受けてください。

### （２）入所決定後の提出書類について

・入所が決定した方には「放課後児童クラブ入所承認通知書（第４号様式）」と併せて、お子さんの状況や緊急時の対応における確認を行うための書類に必要事項を記入のうえ、入所者説明会時等に各公設放課後児童クラブに提出してください。

### （３）持ち物

①入所時に用意していただくもの（主なもの）

・上ばき（学校とは別のもの）
・タオル
・着替え袋（下着・靴下も含めた着替え一式）
・汚れたものを持ち帰るビニール袋
・防災ずきん又はヘルメット（学校とは別のもの）
・雑巾（１枚）

②土曜日や長期休暇など

・リュックなどのカバン
・学習するもの（学習の時間に使用します。）
・お弁当・水筒

③របស់យកមករាល់លើក

・សៀវភៅទំនាក់ទំនង (រៀបចំនៅក្លឹបកុមារ)

※ ដាច់ខាតសូមយកមកនៅថ្ងៃមករៀន។ សូមពិនិត្យថាមានឬគ្មានសរសេរ និងពាក្យផ្ដែផ្ដាំ

・កន្សែងដៃនិងក្រដាសជូត

**※លើរបស់យកមក សូមសរសេរឈ្មោះ។ (ក្រណាត់ជូត មិនចាំបាច់សរសេរទេ)**

**※របស់មិនត្រូវយកមកសាលា គឺដូចគ្នានឹងក្លឹបកុមារក្រោយម៉ោងសាលាដែរ។**

**※លុយនិងប្រដាប់ប្រដារលេង សូមកុំយកមក។**

**※ យើងមិនទទួលខុសត្រូវចំពោះការបាត់និងលួចទេ។**

**※ ក្នុងពេលឈប់សម្រាករយៈពេលយូរឬពិធីសាលា អាចនឹងតម្រូវឱ្យរៀបចំរបស់ផ្សេងដែលកំណត់ដោយក្លឹប។**

## (4) អំពីការជូននិងទទួលកូន

①ប្រការប្រុងប្រយ័ត្នចំពោះការជូននិងទទួលកូន

・ក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ គឺជាគោលកុមារត្រូវទៅសាលារៀនដោយខ្លួនឯង។ **<u>សូមធានាសុវត្ថិភាពកូនអ្នកពេលធ្វើដំណើរទៅមក។ អាណាព្យាបាលត្រូវមកទទួលកូនក្រោយម៉ោង5ល្ងាច។</u>**

・ប្រសិនបើកុមារត្រូវត្រលប់ទៅផ្ទះដោយខ្លួនឯងមុនម៉ោង5:00ល្ងាច ដោយសារថ្ងៃឆាប់លិចពេលរដូវរងា ដូច្នេះសូមចាកចេញពីក្លឹបកុមារក្រោយម៉ោងសាលាឱ្យបានឆាប់ ដើម្បីឱ្យកុមារអាចត្រឡប់មកផ្ទះវិញមុនពេលថ្ងៃលិច។

・ត្រូវប្រាកដថាមកយកកូនត្រឹមម៉ោង7យប់ (ត្រឹមម៉ោង8យប់ ប្រសិនបើអ្នកដាក់ពាក្យសុំមើលថែបន្ថែមម៉ោង)។

・នៅថ្ងៃសៅរ៍ និងថ្ងៃឈប់សម្រាកយូរ **<u>កុមារត្រូវបានហាមឃាត់មិនឱ្យធ្វើដំណើរទៅសាលារៀនដោយជិះកង់ ឬស្បែកជើងសង្រែក ព្រោះវាមានគ្រោះថ្នាក់</u>**។

・ពេលក្លឹបកុមារក្រោយម៉ោងសាលា"បើក" ដោយសារតែការបិទសាលារៀនដោយសារគ្រោះមហន្តរាយដូចជាការរញ្ជួយដី និងខ្យល់ព្យុះ, **<u>អាណាព្យាបាលចាំបាច់ជូននិងមកទទួលកូន។</u>**

②វិធីជូននិងមកទទួល

【ការប្រើប្រាស់កង់នៃអាណាព្យាបាល】

សូមប្រើចំណតកង់នៅមណ្ឌលនីមួយៗ។ ចំណតកង់គួរប្រើជាបណ្ដោះអាសន្នតែពេលជូននិងមកទទួល ហើយសូមកុំចតទុកយូរ។

【ការមកដោយរថយន្តនៃអាណាព្យាបាល】

សូមចតនៅកន្លែងចតរថយន្តដែលបានកំណត់នៅមណ្ឌលនីមួយៗ។ សូមជៀសវៀងចតរថយន្តក្នុងរយៈពេលយូរ ដោយសម្រាប់តែប្រើប្រាស់បណ្ដោះអាសន្ននៅពេលជូននិងមកទទួល។ម្យ៉ាងទៀតពេលចតរថយន្ត សូមប្រយ័ត្នចំពោះការដែលក្មេងនៅជុំវិញ និងប្រយ័ត្នកុំឲ្យមានគ្រោះថ្នាក់។

③毎回持ってきてもらうもの

・連絡帳（児童クラブで用意）

※通所する日は必ず持ってきてください。記入の有無やおたより等の確認をしてください。

・ハンカチ・ティッシュ

**※持ち物には、必ず名前を記入してください。（雑巾には不要）**

**※学校に持ってきていけないものは、放課後児童クラブも同様です。**

**※お金や遊び道具は持参しないでください。**

**※紛失・盗難等については責任を負えませんのでご了承ください。**

**※長期休暇やイベント時には、別途クラブで指定するものを用意いただく場合があります。**

（４）児童の送迎について

①送迎での注意事項

・公設放課後児童クラブは児童自身で通所することを基本としています。往復時のお子様の安全指導を徹底してください。なお、**午後５時以降は保護者のお迎えが必須となります。**

・午後５時前に児童１人で帰宅させる場合には、冬季等は日没時間が早くなるため、日没前には帰宅できるよう、公設放課後児童クラブを出る時間を早めてください。

・午後７時までに必ずお迎えをお願いします（延長保育の申請をされた場合は午後８時まで）。

・土曜日や長期休みなどの際は、**児童の自転車やサンダルによる通所は危険ですので、禁止しています**。

・地震や台風などの災害による学校休校に伴う公設放課後児童クラブ「**開所**」時については、**保護者の送迎を必須とします。**

②送迎の方法

【保護者の方の自転車の利用について】

各施設の駐輪場においてください。駐輪は送迎時の一時的利用のみとし、長時間の駐輪はご遠慮ください。

【保護者の方の車での来所について】

各施設の指定された駐車場においてください。駐車は送迎時の一時利用のみとし、長時間の駐車はご遠慮ください。また、駐車の際は周りにお子さまがいないかなど注意いただき、事故のないよう安全に十分お気をつけください。

【ចំណតរថយន្តនៅក្លឹបកុមារក្រោយម៉ោងសាលា】

| ឈ្មោះក្លឹប | ចំនួនក្នុងចំណត | ទីកន្លែង |
|---|---|---|
| ក្លឹបកុមារក្រោយម៉ោងសាលាបឋមអាយាសិ | 3គ្រឿង | ចំណតរថយន្តភ្ញៀវនៅខាងសាលអប់រំកាយ |
| ក្លឹបកុមារក្រោយម៉ោងសាលាNagagutsu | 3គ្រឿង | ចំណតរថយន្តក្នុងផ្ទះសម្រាកនៃអ្នកចាស់ជរាRyosei**(អាចប្រើចាប់ពីម៉ោង16ល្ងាច និងពីម៉ោង7:30ដល់9ព្រឹក)** |
| ក្លឹបកុមារក្រោយម៉ោងសាលាបឋមTsuchidana | 3គ្រឿង | ចូលតាមទ្វាខាងជើងសាលា ចំណតរថយន្តនៅខាងសាលាអប់រំកាយ(ខាងកើត) |

※ចំពោះក្លឹបកុមារក្រោយម៉ោងសាលាបឋមOchiai, អាចជូននិងមកទទួលដោយរថយន្ត ប៉ុន្តែសូមមេត្តាអធ្យាស្រ័យតាមតែអាចធ្វើទៅបាន ព្រោះចំណតរថយន្តក្នុងសាលាតូចចង្អៀត។

### ③អំពីអាណាព្យាបាលដែលជូននិងមកទទួល

・ដោយគិតពីសុវត្ថិភាពរបស់កុមារ, ការជូននិងមកទទួលនៅក្លឹបកុមារក្រោយម៉ោងសាលាត្រូវធ្វើឡើងដោយអាណាព្យាបាលឬអ្នកជំនួសពេញវ័យដែលដាក់ពាក្យថាមកទទួល។

・ក្នុងករណីជៀសមិនរួចដែលអ្នកផ្សេងមកទទួល សូមប្រាប់យើងជាមុនដោយបំពេញឈ្មោះ អាយុ ភេទជាដើមនៅក្នុងសៀវភៅទំនាក់ទំនង។ ប្រសិនបើមិនមានរបាយការណ៍ទេ យើងនឹងបញ្ជាក់តាមទូរស័ព្ទ និងប្រគល់ឱ្យ នៅពេលអាចបញ្ជាក់បានប៉ុណ្ណោះ។

・ប្រសិនបើមិនអាចទៅទទួលកូន តាមពេលវេលាដែលបានកំណត់ដោយសារមានអាសន្ន ដាច់ខាតសូមទាក់ទងទៅក្លឹបកុមារក្រោយម៉ោងសាលាឱ្យបានឆាប់។

・អាណាព្យាបាលឬអ្នកជំនួសពេញវ័យត្រូវតែជូននិងមកទទួល ចំពោះកុមារដែលកំពុងរៀននៅថ្នាក់បំប៉នពិសេស ឬកុមារដែលត្រូវការជំនួយពិសេស។

## (5) អំពីជំងឺឆ្លងជាដើម

・ក្នុងករណីមានជំងឺឆ្លងដែលនាំឱ្យផ្អាកមកសាលា កុមារមិនអាចប្រើប្រាស់ក្លឹបសាធារណៈក្រោយម៉ោងសាលាសាធារណៈទេ។

・ដើម្បីបន្តការមើលថែឡើងវិញសម្រាប់កុមារដែលបានជាសះស្បើយពីជំងឺ អាណាព្យាបាលចាំបាច់ដាក់ឯកសារបញ្ជាក់អំពីការជាសះស្បើយ។

・ជំងឺគោលដៅ៖ ស្រឡទែន ជំងឺអុតស្វាយ កញ្ច្រឹល ស្អូច ជាដើម។ (គ្រុនផ្តាសាយ, មេរោគឆ្លង streptococcal, ជំងឺដៃជើងនិងមាត់, ជំងឺឆ្លង erythema(ក្រហមស្បែក) ។ល។ មិនត្រូវការលិខិតបញ្ជាក់ការជាសះស្បើយទេ។ )

## (6) អំពីករណីបិទថ្នាក់សិក្សា

・កុមារនៅក្នុងថ្នាក់ដែលត្រូវបានបិទដោយសារតែវីរុសកូរ៉ូណាប្រភេទថ្មី ឬជំងឺគ្រុនផ្តាសាយ មិនអាចប្រើប្រាស់ក្លឹបក្រោយម៉ោងសាលាសាធារណៈនោះទេ ដើម្បីការពារការរីករាលដាលនៃការឆ្លងមេរោគ។

・ក្នុងករណីមានការបិទថ្នាក់រៀន ឬការបិទសាលា ដោយសារវីរុសកូរ៉ូណាប្រភេទថ្មី ឬជំងឺគ្រុនផ្តាសាយ វិធានការខាងក្រោមនឹងត្រូវធ្វើឡើង។

【各放課後児童クラブ駐車場】

| クラブ名 | 駐車場台数 | 場所 |
|---|---|---|
| 綾瀬小放課後児童クラブ | ３台 | 体育館横　来賓駐車場 |
| ながぐつ放課後児童クラブ | ３台 | 綾西高齢者憩いの家　駐車場<br>**（夕方は１６時以降、朝は7時30分から９時まで利用可能）** |
| 土棚小放課後児童クラブ | ３台 | 学校北門から入り<br>体育館横（東側）　駐車場 |

※落合小放課後児童クラブについては、車での送迎は可能ですが、学校内の駐車スペースが狭いため、極力ご遠慮いただくようお願いします。

③送迎される保護者等について

・公設放課後児童クラブへの送迎は必ず、児童の安全を考え、事前にお迎えに来る方として申請いただいている保護者又は成人の代理人が行ってください。

・やむを得ず別の方がお迎えに来る場合には、連絡帳等にて氏名、年齢、性別等を記入いただくなど事前に報告してください。
報告がない場合はお電話にて確認をとり、確認がとれた場合のみ引き渡すこととします。

・緊急の事情により予定の時間までにお迎えができない場合は、早めに必ず公設放課後児童クラブへ連絡をしてください。

・特別支援学級に在籍している等、特別に支援が必要な児童については、必ず、保護者又は成人の代理人が送迎してください。

## （５）感染症などについて

・学校出席停止となる感染症にかかった場合は、公設放課後児童クラブを利用できません。

・疾病完治による児童の再保育開始をするにあたっては、保護者からの治癒証明を書面にて提出していただく必要があります。

・対象となる疾病：流行性耳下腺炎（おたふくかぜ）、水痘（みずぼうそう）、麻疹（はしか）、風疹（みっかはしか）など。（**感染症であってもインフルエンザ・溶連菌感染症・手足口病・伝染性紅斑（りんご病）などの場合には治癒証明書は不要です。**）

## （６）学級閉鎖等の場合について

・新型コロナウイルスやインフルエンザなどにより、学級閉鎖となったクラスの児童は、感染拡大防止のため、公設放課後児童クラブを利用できません。

・新型コロナウイルスやインフルエンザなどによる学級閉鎖、休校の場合においては、次のような対応といたします。

【ករណីបិទថ្នាក់រៀន ឬផ្អាកសាលាដោយសារវីរុសក្សរ៍ណាប្រភេទថ្មី ឬគ្រុនផ្តាសាយជាដើម】

| ពេញចេញប្រកាស | វិធានការ | ដំណោះស្រាយ |
|---|---|---|
| ពេលនៅសាលាថ្ងៃនោះ | ផ្អាកសាលា | ប្រសិនបើសុខភាពរបស់សមីខ្លួនអាចបញ្ជាក់បាន ការមើលថែកុមារនឹងបន្តដូចធម្មតា។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមានអារម្មណ៍មិនស្រួលខ្លួនបន្ទាប់ពីនោះ សូមអាណាព្យាបាលឬអ្នកជំនួស មកទទួលឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។។ |
| | បិទថ្នាក់រៀន | |
| ចាប់ពីថ្ងៃបន្ទាប់ | ផ្អាកសាលា | បិទក្លឹបកុមារក្រោយម៉ោងសាលា។ ដូចសាលារៀនដែរ កុមារមិនអាចចូលក្លឹបក្រោយម៉ោងសាលាបានទេ។ |
| | បិទថ្នាក់រៀន | កុមារដែលចូលរៀនក្នុងថ្នាក់ដែលការបិទថ្នាក់ត្រូវបានប្រកាស ដូចសាលាដែរគឺមិនអាចចូលក្លឹបក្រោយម៉ោងសាលាទេ។ |

## (7) អំពីគ្រោះមហន្តរាយដូចជារញ្ជួយដី និងខ្យល់ព្យុះជាដើម

・ទោះបីជាសាលាបឋមត្រូវបិទដោយសារគ្រោះមហន្តរាយដូចជារញ្ជួយដី ឬខ្យល់ព្យុះក៏ដោយ ក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈនៅ"បើក"។ <u>លើសពីនេះទៀត ប្រសិនបើវាត្រូវបានវិនិច្ឆ័យថាវាពិបាកសម្រាប់កូនក្នុងការទៅផ្ទះតែម្នាក់ឯងដោយសារតែខ្យល់ព្យុះ ឬហេតុផលផ្សេងទៀតក្នុងអំឡុងពេលមើលថែកុមារ យើងអាចសុំឱ្យឪពុកម្តាយមកទទួលកូន។ ព័ត៌មានលម្អិត មានដូចខាងក្រោម។</u>

【អំពីដំណោះស្រាយពេលកើតមានគ្រោះមហន្តរាយ។ល។】

1. ករណីកុមារនៅ"សាលា"

| ប្រភេទមហន្តរាយ | ស្ថានភាពមហន្តរាយ | ដំណោះស្រាយនៅក្លឹបកុមារក្រោយម៉ោងសាលា |
|---|---|---|
| រញ្ជួយដី | នៅពេលកើតមានរញ្ជួយដីចាប់ពីកម្រិត5 ឬសេចក្តីប្រកាសអាសន្នក្នុងទីក្រុង | ជាគោល ក្លឹបកុមារក្រោយម៉ោងសាលានៅ"បើក" ប៉ុន្តែអាស្រ័យលើស្ថានភាព យើងអាចទាក់ទងទៅអាណាព្យាបាល និងសុំឱ្យអាណាព្យាបាលឬអ្នកជំនួសមកទទួល។<br><br>លើសពីនេះ ប្រសិនបើគ្រូបង្គោលនៅក្លឹបកុមារក្រោយម៉ោងសាលា ពិបាកមកធ្វើការ, កន្លែងនោះអាចនឹងត្រូវ"បិទ"។ |
| | ក្រៅពីខាងលើ | |
| អាកាសធាតុអាក្រក់ (ភ្លៀងខ្លាំង, ទឹកជំនន់, ខ្យល់ព្យុះ, ព្រិលខ្លាំង) | នៅពេល"ការព្រមាន(ភ្លៀងខ្លាំង, ទឹកជំនន់, ខ្យល់ព្យុះ, ព្រិលខ្លាំង)" ត្រូវបានប្រកាសនៅ"ទីក្រុងអាយាសិ" ឬអាកាសធាតុអាក្រក់ផ្សេងទៀត | |
| ផ្សេងទៀត | កើតមានការសង្ស័យផ្សេង ក្រៅពីការលើកឡើងខាងលើ | |

【新型コロナウイルス・インフルエンザなどによる学級閉鎖、休校の場合】

| 発令のタイミング | 措　置 | 対　　　　　応 |
|---|---|---|
| 当日在校時 | 休　校 | 本人の健康が確認できれば、通常どおり保育します。<br>ただし、その後体調不良が見受けられた場合は、保護者又は代理人の方の速やかなお迎えをお願いします。 |
| | 学級閉鎖 | |
| 翌日以降 | 休　校 | 放課後児童クラブ閉所。学校同様、放課後児童クラブにも通所できません。 |
| | 学級閉鎖 | 学級閉鎖が発令されたクラスに在籍する入所児童は、学校同様、放課後児童クラブにも通所できません。 |

## （7）地震、台風などの災害について

- 地震や台風などの災害により、小学校が休校になった場合であっても、公設放課後児童クラブは「開所」します。なお、保育時間中に台風などの事由により、児童１人での帰宅が困難であると判断される場合は、保護者の方にお迎えをお願いすることがあります。
  詳細については、次のとおりです。

【災害発生時等の対応について】

１．児童が「学校」にいる場合

| 災害の種類 | 災害状況 | 放課後児童クラブの対応 |
|---|---|---|
| 地震 | 市内で震度５弱以上の地震発生又は警戒宣言が発令された場合 | 基本的に、放課後児童クラブを「開所」しますが、状況に応じて保護者に連絡し、保護者又は代理人の方にお迎えをお願いする場合があります。<br>なお、放課後児童クラブ指導員が出勤することが困難な状況の場合等は「閉所」することがあります。 |
| | 上記以外 | |
| 悪天候<br>（大雨・洪水・暴風・大雪） | 「警報（大雨・洪水・暴風・大雪）」が「綾瀬市」に発令された場合、その他悪天候の場合 | |
| その他 | 不審者の発生など上記以外 | |

2. ករណីកុមារនៅក្លឹបក្រោយម៉ោងសាលា

| ប្រភេទមហន្តរាយ | ស្ថានភាពមហន្តរាយ | ដំណោះស្រាយនៅក្លឹបកុមារក្រោយម៉ោងសាលា |
|---|---|---|
| រញ្ជួយដី | នៅពេលកើតមានរញ្ជួយដីចាប់ពីកម្រិត5 ឬសេចក្តីប្រកាសអាសន្នក្នុងទីក្រុង | ក្លឹបកុមារក្រោយម៉ោងសាលានឹងនៅតែ"បើក" រហូតដល់កុមារទាំងអស់ត្រូវបានប្រគល់ទៅឱ្យអាណាព្យាបាល។ សូមអាណាព្យាបាលឬអ្នកជំនួស មកទទួលកុមារភ្លាមៗនៅក្លឹបក្រោយម៉ោងសាលា។ ※ប្រសិនបើកន្លែងជម្លៀសត្រូវបានរៀបចំ កុមារអាចត្រូវបានផ្លាស់ទៅមជ្ឈមណ្ឌលជម្លៀស។ ក្នុងករណីនោះ យើងនឹងបិទផ្សាយសេចក្តីប្រកាសនោះនៅច្រកចូលក្លឹបកុមារក្រោយម៉ោងសាលា។ |
| | ក្រៅពីខាងលើ | ក្លឹបកុមារក្រោយម៉ោងសាលានៅ"បើក" ប៉ុន្តែអាស្រ័យលើស្ថានភាព យើងអាចទាក់ទងទៅអាណាព្យាបាល និងសុំឱ្យអាណាព្យបាលឬអ្នកជំនួសឆាប់មកទទួល តាមដែលអាចធ្វើទៅបាន។ |
| អាកាសធាតុអាក្រក់ (ភ្លៀងខ្លាំង, ទឹកជំនន់, ខ្យល់ព្យុះ, ព្រិលខ្លាំង) | | |
| ផ្សេងទៀត | កើតមានការសង្ស័យផ្សេងក្រៅពីខាងលើ | |

3. ករណីកុមារនៅផ្ទះ(មុនមកសាលា)

| ប្រភេទមហន្តរាយ | ស្ថានភាពមហន្តរាយ | ដំណោះស្រាយនៅក្លឹបកុមារក្រោយម៉ោងសាលា |
|---|---|---|
| រញ្ជួយដី | នៅពេលកើតមានរញ្ជួយដីចាប់ពីកម្រិត5 ឬសេចក្តីប្រកាសអាសន្នក្នុងទីក្រុង | (ករណីផ្អាកសាលា)<br>ក្លឹបក្រោយម៉ោងសាលានៅ"បើក"។<br><br>(ករណីសាលាពន្យាពេលឱ្យមកសាលា)<br>ជាគោល "បើក" តាមធម្មតា(ក្រោយចប់ថ្នាក់រៀននៅសាលា)។<br><br>(ចំថ្ងៃឈប់សម្រាកថ្នាក់រៀនសាលា)<br>ក្លឹបក្រោយម៉ោងសាលានៅ"បើក"។<br><br>លើសពីនេះ ទោះនៅ"បើក"ក្លឹបក្រោយម៉ោងសាលាក៏ដោយ ប្រសិនបើគ្រូបង្គោល ពិបាកមកធ្វើការ, កន្លែងនោះអាចនឹងត្រូវ"បិទ"។ |
| | ក្រៅពីខាងលើ | |
| អាកាសធាតុអាក្រក់ (ភ្លៀងខ្លាំង, ទឹកជំនន់, ខ្យល់ព្យុះ, ព្រិលខ្លាំង) | នៅពេល"ការព្រមាន(ភ្លៀងខ្លាំង, ទឹកជំនន់, ខ្យល់ព្យុះ, ព្រិលខ្លាំង)" ត្រូវបានចេញផ្សាយក្នុង"ទីក្រុងអាយាសិ" ដោយព័ត៌មានទិន្នន័យ (ព័ត៌មានអាកាសធាតុ) នៃការផ្សាយតាមប្រព័ន្ធឌីជីថលលើដីNHK នៅម៉ោង7:00ព្រឹកនៅថ្ងៃទៅសាលា។ល។ | |
| ផ្សេងទៀត | កើតមានការសង្ស័យផ្សេងក្រៅពីខាងលើ | |

※វិធីទំនាក់ទំនង គឺតាមទូរសព្ទឬផ្ញើម៉ែល។

## ２．児童が放課後児童クラブにいる場合

<table>
<tr><th>災害の種類</th><th>災害状況</th><th>放課後児童クラブの対応</th></tr>
<tr><td rowspan="2">地震</td><td>市内で震度５弱以上の地震発生又は警戒宣言が発令された場合</td><td>放課後児童クラブは児童全員を保護者等に引き渡すまで「開所」しますが、保護者又は代理人の方は速やかに放課後児童クラブへ迎えに来てください。<br>※避難所が開設された場合は、児童は避難所へ移動することがあります。その場合は放課後児童クラブ入口にその旨の掲示をします。</td></tr>
<tr><td>上記以外</td><td rowspan="3">放課後児童クラブは「開所」しますが、状況に応じて保護者に連絡し、保護者又は代理人の方に速やかなお迎えをお願いする場合があります。</td></tr>
<tr><td colspan="2">悪天候（大雨・洪水・暴風・大雪）</td></tr>
<tr><td>その他</td><td>不審者の発生など上記以外</td></tr>
</table>

## ３．児童が自宅（登校前）にいる場合

<table>
<tr><th>災害の種類</th><th>災害状況</th><th>放課後児童クラブの対応</th></tr>
<tr><td rowspan="2">地震</td><td>市内で震度５弱以上の地震発生又は警戒宣言が発令された場合</td><td rowspan="4">（学校が休校の場合）<br>放課後児童クラブは「開所」します。<br><br>（学校が登校を遅らせた場合）<br>原則として、通常通り（学校の授業の終了後より）「開所」します。<br><br>（学校の授業の休業日）<br>放課後児童クラブは「開所」します。<br><br>なお、放課後児童クラブを「開所」する場合であっても、指導員が出勤することが困難な状況の場合等は「閉所」することがあります。</td></tr>
<tr><td>上記以外</td></tr>
<tr><td>悪天候<br>（大雨・洪水・暴風・大雪）</td><td>登校日の午前７時時点のＮＨＫ地上デジタル放送のデータ情報（気象情報）で「警報（大雨・洪水・暴風・大雪）」が「綾瀬市」に発令された場合等</td></tr>
<tr><td>その他</td><td>不審者の発生など上記以外</td></tr>
</table>

※連絡手段については、電話連絡やメール配信となります。

## 4 អំពីសកម្មភាពនៅក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ

### (1) សកម្មភាពពេញ1ថ្ងៃ(ឧទាហរណ៍)

| | |
|---|---|
| 【ថ្ងៃធម្មតា】 បើកក្រោយម៉ោងសាលា<br>ក្រោយម៉ោងសាលា ដល់ 16:00 ទៅកន្លែងតាមលំដាប់<br>ក្រោយម៉ោងសាលា ដល់ 16:30 ម៉ោងសិក្សា<br>ក្រោយម៉ោងសាលា ដល់ 16:30 លេងសេរី<br>16:30 ដល់ 17:00 អាហារសម្រន់ / បោសសំអាត<br>17:00 ដល់ 19:00 លេងសេរី<br>19:00 ដល់ 20:00 មើលថែបន្ថែមម៉ោង<br>ត្រលប់ទៅផ្ទះតាមលំដាប់<br>・ម៉ោងបើកគឺផ្លាស់ប្តូរតាមម៉ោងចុះពីសាលា<br>・ក្នុងករណីពិធីបើកបវេសនកាល ឬថ្នាក់រៀនបង្រួមពេល, ការបើកនឹងមានមុន។ | 【ថ្ងៃសៅរ៍ជាដើម】 បើក:8:00<br>8:00 ដល់ 9:00 ទៅកន្លែងតាមលំដាប់<br>9:00 ដល់ 10:00 ម៉ោងសិក្សា<br>10:00 ដល់ 12:00 លេងសេរី<br>12:00 ដល់ 12:30 អាហារថ្ងៃត្រង់<br>12:30 ដល់ 13:00 សម្រាក<br>13:00 ដល់ 15:30 លេងសេរី<br>15:30 ដល់ 16:00 អាហាសម្រន់ / បោសសំអាត<br>16:15 ដល់ 19:00 លេងសេរី<br>19:00 ដល់ 20:00 មើលថែបន្ថែមម៉ោង<br>ត្រលប់ទៅផ្ទះតាមលំដាប់<br>・សកម្មភាពក្នុងថ្ងៃឈប់សម្រាកនៃសាលា(ថ្ងៃសៅរ៍, វិសមកាលរដូវក្តៅជាដើម) |

**※សកម្មភាពពេញ1ថ្ងៃខុសគ្នាទៅតាមក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈនិមួយៗ**
**※ការគ្រប់គ្រងក្លឹប ត្រូវបានធ្វើឡើងដោយប្រតិបត្តិករដែលក្រុងពឹងពាក់។**

### (2) ការរៀបចំបិនតូ

・ខុសពីទារកដ្ឋានជាដើម, ក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈ មិនមានកន្លែងចម្អិនអាហារទេ។ ដាច់ខាតសូមឱ្យកូនយកបិនតូ សម្រាប់ថ្ងៃឈប់សម្រាកនៃសាលា(ថ្ងៃសៅរ៍, វិសមកាលរដូវក្តៅ។ល។) ឬថ្ងៃដែលមិនមានផ្តល់អាហារនៅសាលាបឋម។

※អាហារសម្រន់នឹងត្រូវបានផ្តល់ជូន។

### (3) ការហាមឃាត់ចេញកណ្តាលម៉ោង

・ក្រោយមានវត្តមាននៅក្លឹបក្រោយម៉ោងសាលាសាធារណៈ កុមារអាចទៅសាលាបំប៉នឬទៅរៀនបន្ថែម ប៉ុន្តែពួកគេមិនអាចត្រឡប់ទៅក្លឹបក្រោយម៉ោងសាលាវិញបានទេ។



# ４　公設放課後児童クラブでの過ごし方について

## （１）１日の過ごし方（例）

| 【平日】　開所：放課後 | 【土曜日など】　開所：8:00 |
|---|---|
| 放課後～16:00・・・・・順次通所<br>放課後～16:30・・・・・学習時間<br>放課後～16:30・・・・・自由遊び<br>16:30～17:00・・・・・おやつ・掃除<br>17:00～19:00・・・・・自由遊び<br>19:00～20:00・・・・・延長保育<br>順次帰宅<br>・開所時間は学校の下校時間に合わせて、変更します。<br>・始業式、短縮授業等の場合は開所が早くなります。 | 8:00～9:00・・・・・順次通所<br>9:00～10:00・・・・学習時間<br>10:00～12:00・・・・自由遊び<br>12:00～12:30・・・・昼食<br>12:30～13:00・・・・休憩<br>13:00～15:30・・・・自由遊び<br>15:30～16:00・・・・おやつ・掃除<br>16:15～19:00・・・・自由遊び<br>19:00～20:00・・・・延長保育<br>順次帰宅<br>・学校休業日（土曜日、夏休み等）の過ごし方です。 |

**※１日の過ごし方は、各公設放課後児童クラブによって異なります。**
**※クラブの運営は、市が委託する事業者が行います。**

## （２）お弁当の用意

・公設放課後児童クラブは、保育所等と違い調理施設がありません。学校休業日（土曜日、夏休み等）又は小学校で給食のない日には、必ずお弁当を持たせてください。
※おやつの提供は行います。

## （３）中抜けの禁止

・児童は、公設放課後児童クラブに出席した後に塾や習い事等へ行くことはできますが、再び公設放課後児童クラブに戻ってくることはできません。



## 5 អំពីការដោះស្រាយពេលអាសន្ន

### (1) អំពីដំណោះស្រាយនៃការហ្វឹកហាត់ជម្លៀសនៅសាលា និងការចុះពីសាលាជាក្រុម

・មារអាចត្រូវបានជ្រើសរើសដោយគ្រូបង្គោលពីក្លឹបក្រោយម៉ោងសាលាសាធារណៈ។

**※ប្រសិនបើចង់បាន ការប្រគល់កូនតាមរយៈគ្រូបង្គោលនៃក្លឹបក្រោយម៉ោងសាលាសាធារណៈ ចាំបាច់ជូនដំណឹងទៅសាលា។**

**※នៅក្លឹបក្រោយម៉ោងសាលាសាធារណៈក៏មានអនុវត្តហ្វឹកហាត់បង្ការគ្រោះមហន្តរាយផងដែរ (ហ្វឹកហាត់ជម្លៀសកុមារ និងហ្វឹកហាត់ប្រគល់កូនទៅអាណាព្យាបាល។ល។)។ សូមអគុណដល់កិច្ចសហការរបស់អ្នក។**

### (2) ករណីជំងឺនៃកុមារ និងពេលអាសន្នផ្សេងទៀត

・ក្លឹបក្រោយសាលាសាធារណៈ ជាគោលមិនអាចរក្សាទុកថ្នាំពេទ្យទេ។ (ចំពោះករណីចាំបាច់បំផុត កុមារអាចប្រើប្រាស់ថ្នាំពេទ្យដោយខ្លួនឯង **ដោយពុំចាំបាច់ការជួយពីគ្រូបង្គោល។**)

・ក្នុងករណីកុមារមិនអាចចូលរួមក្នុងសកម្មភាពក្លឹបក្រោយម៉ោងសាលាសាធារណៈ ដោយសារជំងឺ ឬហេតុផលផ្សេងទៀត យើងនឹងទាក់ទងទៅអាណាព្យាបាល សូមមកទទួលកុមារ។

・បន្ថែមពីនេះ ប្រសិនបើយើងមិនអាចទាក់ទងអាណាព្យាបាលបានទេ យើងអាចទាក់ទងអ្នកដែលបានបំពេញឯកសារប្រគល់ឱ្យបន្ទាប់ពីការសម្រេចចូលរៀន ហើយសុំឱ្យមកទទួលកូន។

## 6 ពាក្យជូនដំណឹងអំពីការផ្លាស់ប្តូរ និងពាក្យជូនដំណឹងអំពីឈប់ចេញពីសាលា

### (1) ការផ្លាស់ប្តូរអាសយដ្ឋាន និងស្ថានភាពការងារ។ល។

・ក្នុងករណីមានការផ្លាស់ប្តូរខ្លឹមសារដែលបានបំពេញក្នុងពាក្យសុំ(អាសយដ្ឋាន, គ្រួសារ, ស្ថានភាពការងារ(ផ្លាស់ប្តូរម៉ោងធ្វើការ, ផ្លាស់ប្តូរទីកន្លែងធ្វើការ, ចូលនិវត្តន៍។ល។)) សូមដាក់"ពាក្យជូនដំណឹងផ្លាស់ប្តូរប្រើប្រាស់ក្លឹបកុមារក្រោយម៉ោងសាលា(ទម្រង់លេខ9)"មកផ្នែកមើលថែកុមារ។ ហើយប្រសិនបើអ្នកផ្លាស់ប្តូរកន្លែងធ្វើការ សូមដាក់លិខិតបញ្ជាក់ការងារផងដែរ។

**※សូមប្រាប់មកយើង ប្រសិនបើអ្នកបានផ្លាស់ប្តូរព័ត៌មានទំនាក់ទំនង ដូចជាលេខទូរស័ព្ទជាដើម។**

### (2) បែបបទពេលអវត្តមានយូរ និងពេលឈប់ចេញពីសាលា

・ក្នុងករណីអវត្តមានរយៈពេលយូរ(ឈប់សម្រាក)ឬលាឈប់ពីក្លឹបក្រោយម៉ោងសាលា សូមដាក់ "ពាក្យជូនដំណឹងលាឈប់ ឬអវត្តមានរយៈពេលយូរពីក្លឹបក្រោយម៉ោងសាលា(ទម្រង់លេខ10)" មកផ្នែកមើលថែកុមារ។

**※ថ្លៃមើលថែត្រូវបានប្រមូល បើទោះបីដាក់"ពាក្យជូនដំណឹងលាឈប់ ឬអវត្តមានរយៈពេលយូរពីក្លឹបក្រោយម៉ោងសាលា(ទម្រង់លេខ10)" ដោយសារអវត្តមានរយៈពេលយូរក៏ដោយ។**

**※ក្នុងករណីលាឈប់ សូមចំណាំថា ប្រសិនបើមិនដាក់ "ពាក្យជូនដំណឹងលាឈប់ ឬអវត្តមានរយៈពេលយូរពីក្លឹបក្រោយម៉ោងសាលា(ទម្រង់លេខ10)" ទេនោះ នឹងត្រូវបានចាត់ទុកជាអវត្តមាន ហើយថ្លៃមើលថែនឹងត្រូវគិតថ្លៃ។**

## 5　緊急時の対応について

（１）学校の避難訓練、集団下校の対応について

・児童の引き取りには、公設放課後児童クラブの指導員が行くことができます。

**※公設放課後児童クラブの指導員による引き渡しを希望される場合については、学校への届け出を行う必要があります。**

**※公設放課後児童クラブでも、防災訓練（児童の避難訓練及び保護者等への引渡し訓練）を実施します。ご協力をお願いします。**

（２）児童の病気、その他の緊急時の場合

・公設放課後児童クラブでは、薬のお預かりは原則できません。（どうしても必要な場合は、**指導員の介助を必要とせずに**児童自身で薬を使用できる場合のみとします。）

・児童が病気などにより公設放課後児童クラブでの活動に参加できない場合には、保護者宛てに連絡をしますので、お迎えをお願いします。

・また、保護者に連絡が取れない場合には、入所決定後にお渡しする書類等に記入いただいた方に連絡し、お迎えをお願いすることがあります。

## 6　変更届、退所届について

（１）住所や勤務状況等の変更など

・申請書に記載した内容(住所、家族、就労状況(勤務時間変更、勤務先の変更、退職等)など）に変更があった場合は「放課後児童クラブ利用変更届（第９号様式）」を保育課へ提出してください。なお、勤務先の変更の場合はあわせて就労証明書も提出ください。

**※携帯電話等の連絡先に変更があった場合も知らせてください。**

（２）長期の欠席、退所の手続き

・公設放課後児童クラブを長期の欠席（休所）又は退所する場合は、事前に「放課後児童クラブ退所・長期の欠席届（第１０号様式）」を保育課へ提出してください。

**※保育料は、長期の欠席での「放課後児童クラブ退所・長期の欠席届（第１０号様式）」の提出の場合でも徴収させていただきます。**

**※退所する場合は、「放課後児童クラブ退所・長期の欠席届（第１０号様式）」の提出がないと、欠席扱いとなり、保育料がかかりますので注意してください。**

## 7 ផ្សេងទៀត

・ចំពោះការចូលរៀន ឆន្ទះរបស់កុមារខ្លួនឯងមានសារៈសំខាន់ណាស់។ ដាច់ខាតសូមពិគ្រោះរវាងឪពុកម្ដាយនិងកូន មុនដាក់ពាក្យសុំចូលរៀន។

・ជាគោល អាណាព្យាបាលនឹងតម្រូវឱ្យទទួលបន្ទុកលើថ្លៃជួសជុល បន្ទាប់ពីកុមារចូលរៀន និងធ្វើឱ្យខូចខាតសម្ភារៈរបស់សាលា ឬកន្លែងផ្សេងៗទៀត។

・ក្នុងករណីមិនអាចគោរពអនុវត្តតាមច្បាប់របស់ក្លឹបក្រោយម៉ោងសាលាសាធារណៈ (មិនអាចមកទទួលកុមារត្រឹមចប់ម៉ោងបើក, មិនបង់ថ្លៃមើលថែ។ល។)ទេ អាចប៉ះពាល់ដល់ការដាក់ពាក្យចូលរៀននៅឆ្នាំបន្ទាប់។

・បន្ថែមលើការផ្ទុសទិដ្ឋភាពរបស់ក្លឹបក្រោយម៉ោងសាលាសាធារណៈនៅលើព្រឹត្តិប័ត្រឬគេហទំព័ររបស់ទីក្រុង, ប្រតិបត្តិករដែលក្រុងពឹងពាក់ឱ្យគ្រប់គ្រង អាចផ្សព្វផ្សាយទៅខាងក្រៅ ជាលទ្ធផលការងារ ឬការបង្ហាញឧទាហរណ៍។

**※ក្នុងករណីមុខរបស់កុមារជាដើម អាចត្រូវបានកំណត់អត្តសញ្ញាណ យើងនឹងផ្សព្វផ្សាយ ក្រោយពីទទួលបានការយល់ព្រមពីអាណាព្យាបាលដោយឡែកពីគ្នា។**

## 8 ទំនាក់ទំនង

【អ្នកទទួលបន្ទុកមើលថែសិស្សសាលា ផ្នែកមើលថែកុមារ នាយកដ្ឋានសុខភាពកុមារ សាលាក្រុងអាយាសិ】

អាសយដ្ឋាន: 550 Hayakawa, Ayase (អគារច្រកទទួល ជាន់ទី2)

ទូរសព្ទ: 0467-70-5682 [ខលសិនធ័របកប្រែភាសាបរទេសទីក្រុងអាហាសិ]

E-mail: wm.701702@city.ayase.kanagawa.jp



## 7　その他

・入所については、児童本人の意思も重要な部分を占めています。入所申込前に必ず親子で話し合いをしてください。

・入所児童が学校等施設の備品などを破損したときは、原則として保護者に修理代を負担していただきます。

・公設放課後児童クラブでのルールが守れない場合（開所時間終了時刻までに迎えに来られない、保育料の滞納等）、次年度の入所申込において、影響が出る場合があります。

・公設放課後児童クラブでの様子を、市の広報やホームページ等に掲載するほか、市が運営を委託する事業者が事業成果・事例紹介として外部へ公開する場合があります。

**※児童の顔などが特定されるような場合は、別途保護者の方へ承諾をいただいた上で、掲載させていただきます。**

## 8　問い合わせ先

【綾瀬市役所健康こども部保育課保育・学童担当】

住　所：綾瀬市早川５５０番地（窓口棟２階）

電　話：０４６７-７０-５６８２［綾瀬市外国語通訳コールセンター］

E-mail：wm.701702@city.ayase.kanagawa.jp



## 9 បញ្ជីក្លឹបកុមារក្រោយម៉ោងសាលាឯកជនក្នុងក្រុង

នៅក្នុងទីក្រុងមានក្លឹបកុមារក្រោយម៉ោងសាលាឯកជនដែលដំណើរការដោយសមាគមអាណាព្យាបាល។ ដោយសារមានភាពខុសប្លែកគ្នានៅក្នុងលក្ខខណ្ឌនៃការចូលរៀន, វិធីសាស្ត្រគ្រប់គ្រង និងថ្លៃមើលថែកុមារ។ល។ ពីក្លឹបក្រោយម៉ោងសាលាសាធារណៈដែលបង្កើតឡើងដោយទីក្រុង, សូមសាកសួរផ្ទាល់មកក្លឹបក្រោយម៉ោងសាលាឯកជនខាងក្រោម សម្រាប់ការសាកសួរទាក់ទងនឹងការចូលរៀន។

ប្រសិនបើត្រូវការបកប្រែ សូមពិគ្រោះមកខលសិនធ័របកប្រែភាសាបរទេសទីក្រុងអាយាសិ (TEL 0467-70-5682)។

【បញ្ជីក្លឹបកុមារក្រោយម៉ោងសាលាឯកជន】 កូដតំបន់ (0467)

| ឈ្មោះក្លឹបក្រោយម៉ោង | តំបន់សាលាសំខាន់ | អាសយដ្ឋាន | ទូរសព្ទ |
|---|---|---|---|
| Wanpaku Club | បឋមអាយាសិ | 5-3-70 Fukayakami | 77-5408 |
| Aozora Club | បឋម Ryohoku | 1-4-70 Teraonaka | 78-4412 |
| Sukoyaka Club | បឋមRyosei | 1403-2 Hayakawa | 77-0383 |
| Himawari Club | បឋមRyosei | 4-19-3 Ryosei | 73-7938 |
| Tanken Club | បឋមSoen | 407-1 2F Shoen | 70-1678 |
| Otogi Club | បឋមSoen | 3067-5 Hayakawa | 76-3841 |
| Nikoniko Club | បឋមRyonan | 3-5-1 Kamitsuchidanakita | 76-7726 |
| Ayase Izumi Club | បឋមRyonan | 4-11-41 Kamitsuchidanakita | 55-9696 |
| Wakuwaku Club | បឋមTendai | 3-11-1 Teraonishi | 77-3988 |
| Nobikko Clu | បឋមKitanodai | 8-3-5 Ogami | 77-0852 |
| Tanpopo Club | បឋមRyonan បឋម Tsuchidana | 2-9-11 Kamitsuchidanaminami | 38-5383 |
| Genki Club | បឋមTerao | 2-6-17 Teraominami | 76-6364 |



## ９　市内の民設民営放課後児童クラブ一覧

市内には保護者会等が運営を行う民設民営の放課後児童クラブがあります。市が開設する公設放課後児童クラブとは入所条件や運営方法、保育料などの違いがありますので、入所等に関する問い合わせについては、以下の民設民営放課後児童クラブへ直接お問い合わせください。

通訳が必要な場合は綾瀬市外国語通訳コールセンター（TEL0467-70-5682）へご相談ください。

【民設民営放課後児童クラブ一覧】　　市外局番（０４６７）

| 放課後児童クラブ名 | 主な学区 | 所　在　地 | 電話番号 |
|---|---|---|---|
| わんぱくクラブ | 綾瀬小 | 深谷上５－３－70 | 77-5408 |
| あおぞらクラブ | 綾北小 | 寺尾中１－４－７０ | 78-4412 |
| すこやかクラブ | 綾西小 | 早川 1403－2 | 77-0383 |
| ひまわりクラブ | 綾西小 | 綾西４－19－３ | 73-7938 |
| たんけんクラブ | 早園小 | 小園 407-1　２F | 70-1678 |
| おとぎクラブ | 早園小 | 早川 3067－５ | 76-3841 |
| にこにこクラブ | 綾南小 | 上土棚北３－５－１ | 76-7726 |
| 綾瀬いずみクラブ | 綾南小 | 上土棚北４－11－41 | 55-9696 |
| わくわくクラブ | 天台小 | 寺尾西３－１１－１ | 77-3988 |
| のびっこクラブ | 北の台小 | 大上８－３－５ | 77-0852 |
| たんぽぽクラブ | 綾南小　土棚小 | 上土棚南２－９－11 | 38-5383 |
| げんきクラブ | 寺尾小 | 寺尾南２－６－１７ | 76-6364 |



# ផែនទីទីតាំងក្លឹបកុមារក្រោយម៉ោងសាលាសាធារណៈនិងឯកជនក្នុងក្រុងអាយាសិ



# 綾瀬市公設・民設放課後児童クラブ位置図

